ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៦២០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី

**ការកាត់ដីសរុបទំហំ ៤០៧៩,៥២៦៧ ហិកតា នៅស្រុកបរកែវ និងស្រុកលំផាត់ ខេត្តរតនគិរី ក្នុងនោះ កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជីវ ហ្សុទរី កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ម្ហូដ ពេជ្រ អភិវឌ្ឍន៍ កសិ-ឧស្សាហកម្ម និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេលែវ ចឹអឹម យ៉ញស្តុក កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ស៊ី អ ឌី និង កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ខាសនា អ៊ិនវេសមេន សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋសរុប ៧១៤ គ្រួសារ និងរក្សាទុកមួយចំណែក សម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងការផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី**

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ២២៣/១៣ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១..**

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៥០៧៩.៥២៦៧ ហិកតា ក្នុងនោះ (១) ទំហំ ១៥៧.៧៣៥២ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជីង ហ្សុងរី (២) ទំហំ ៣២.៧៧៩០ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ម្ពុជ ពេជ្រ អភិវឌ្ឍន៍ កសិ-ឧស្សាហាកម្ម និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសរុបទំហំ ១៨០, ៥១៣២ ហិកតា (៣) ទំហំ ២២២៧.៧៥២៨ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេលែរ ប៊ីអឹម យ៉ញស្តុក (៤) ទំហំ ៧៥១.៦៦៤៣ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ស៊ី អ ឌី និង (៥) ទំហំ ៩១៩.៦០៦៤ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វាសនា អ៊ិនវេសមេន សម្រាប់ប្រទានកម្មទំហំ ៣.៦២៨,២០៧៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋនិងទំហំ ៥៥៥,៣១៩២ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅខេត្តរតនគិរី ដែលស្ថិតក្នុងភូមិ ឃុំ ស្រុក ដូចខាងក្រោម៖

១. ឃុំសេរ៉ុង ស្រុកបរកែវ ៖

- កាត់ផ្ទៃដីទំហំ ៧០៩.៥៦៦៧ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេលែវ ប៊ីអឹម យ៉ញស្តុក សម្រាប់ប្រទានកម្មទំហំ ៦៧៨,៩០២៦ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៣០,៦៦៤១ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិយ៉ាសម ។
- កាត់ផ្ទៃដីទំហំ ៦១.៣០៦១ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន អេលែវ ប៊ីអឹម យ៉ញស្តុក សម្រាប់ប្រទានកម្មទំហំ ៥៩,០៩៣១ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២,២១៣ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិសេរ៉ុង ។

២. ឃុំកិះចុង ស្រុកបរកែវ ៖

- កាត់ផ្ទៃដីទំហំសរុប ៣០៧.៥៣១៩ ហិកតា ក្នុងនោះ (១)ទំហំ ២៧៨.៧២៤៦ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ស៊ី អ ឌី និង(២)ទំហំ ២៨.៨០៧៣ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វាសនា អ៊ិនវេសមេន សម្រាប់ធ្វើប្រទានកម្មទំហំ ២៨៧,០៨៦៣ ហិកតា ជាកម្មសិទ្ធិជូន ប្រជាពលរដ្ឋ និងទំហំ ២០,៨៨៥៦ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិប៉ាឡៃ ។
- កាត់ផ្ទៃដីទំហំសរុប ១៣៦៣.៧៣៨៨ ហិកតា ក្នុងនោះ(១)ទំហំ ៨៧២.៩៣៩៧ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ស៊ី អ ឌី និង(២)ទំហំ ៨៩០.៧៩៩១ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន វាសនា អ៊ិនវេសមេន សម្រាប់ធ្វើប្រទានកម្មទំហំ ១.១៨៨,៥១៩៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៧៥,២១៩៣ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅ ភូមិ រ៉យ ។

៣.ឃុំសេដា ស្រុកលំផាត់ ៖

- កាត់ផ្ទៃដីទំហំ ១៤៧.៧៣៤២ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជឹង ហ្សុងរី សម្រាប់ប្រទានកម្មទំហំ ១២២,៣០៣៦ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២៥,៤៣០៦ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនា-សម្ព័ន្ធរូបវន្ត នៅភូមិប៉ាតត់ ។
- កាត់ផ្ទៃដីទំហំ ១១៩៤.៧៧០៦ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ ក្រុមហ៊ុន អេលែវ ប៊ីអឹម យ៉ញស្តុក សម្រាប់ប្រទានកម្មទំហំ ១០០៤,២០៩៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៩០,៥៦១១ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិណងហៃ ។
- កាត់ផ្ទៃដីទំហំ ២៦២.០៩៩៤ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ ក្រុមហ៊ុន អេលែវ ប៊ីអឹម យ៉ញស្តុក សម្រាប់ប្រទានកម្មទំហំ ២៥៤,៣២៣២ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៧,៧៧៦២ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិសមុទ្រក្រោម ។

៤. ឃុំកាឡែង ស្រុកលំផាត់

- កាត់ផ្ទៃដីទំហំ ៣២.៧៧៩០ ហិកតា ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ម្កុដពេជ្រ អភិវឌ្ឍន៍ កសិ-ឧស្សាហកម្ម សម្រាប់ប្រទានកម្មទំហំ ២៩,៨០៩៧ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២,៩៦៩៣ ហិកតា រក្សាទុកសម្រាប់កំណើនប្រជាពលរដ្ឋ និង ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិសាយ៉ស់ ។

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ (១ ដល់ ៨) នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ នៅភូមិយ៉ាសម, ភូមិស៊ើង ឃុំស៊ើង, ភូមិប៉ាឡៃ, ភូមិរ៉យ ឃុំកិះចុង ស្រុកបរកែវ និងភូមិលាងហៃ, ភូមិប៉ាតត់, ភូមិសមុទ្រក្រោម ឃុំសេដា និង ភូមិសាយ៉ស់ ឃុំកាឡែង ស្រុកលំផាត់ ខេត្តរតនគិរី ។

**មាត្រា ៣.-**

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសរុប ៩៧២ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៩៧០ ក្បាលដី ជូនប្រជាពលរដ្ឋ ៦៣៤ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០២ ក្បាលដី នៅខេត្តរតនគិរី ដែលស្ថិតនៅក្នុងភូមិ ឃុំ ស្រុក ដូចខាងក្រោម ៖

១. ឃុំស៊ើង ស្រុកបរកែវ

- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសរុប ២៤៣ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ២៤២ ក្បាលដី ជូនប្រជាពលរដ្ឋ ១៤៣ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០១ ក្បាលដី នៅភូមិយ៉ាសម ។
- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសរុប ២៩ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ២៨ ក្បាលដី ជូនប្រជាពលរដ្ឋ ២៣ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០១ ក្បាលដី នៅភូមិស៊ើង ។

២. ឃុំកិះចុង ស្រុកបរកែវ

- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ១១៥ ក្បាលដី ជូនប្រជាពលរដ្ឋ ៧៣ គ្រួសារ នៅភូមិប៉ាឡៃ។
- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៣០៩ ក្បាលដី ជូនប្រជាពលរដ្ឋ ១៩៩ គ្រួសារ នៅភូមិរ៉យ ។

៣.ឃុំសេដា ស្រុកលំផាត់

- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ២២ ក្បាលដី ជូនប្រជាពលរដ្ឋ ១៥ គ្រួសារ នៅភូមិប៉ាតត់ ។

- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ២៣៩ ក្បាលដី ជូនប្រជាពលរដ្ឋ ១៦៩ គ្រួសារ នៅភូមិណងហៃ ។
- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ០៨ ក្បាលដី ជូនប្រជាពលរដ្ឋ ០៧ គ្រួសារ នៅភូមិសមុទ្រក្រោម ។

៩. ឃុំកាឡែង ស្រុកលំផាត់

- ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ១២ ក្បាលដី ជូនប្រជាពលរដ្ឋ ១១ គ្រួសារ នៅភូមិសាយ៉ស់ ។

**មាត្រា ៤.-**

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តរតនគិរី ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*